**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

# ក្រុមហ៊ុន អេ អាយ អេ ខេមបូឌា និងធនាគារកម្ពុជាសាធារណៈ បន្តភាពជាដៃគូ ដើម្បីជួយអតិថិជនឲ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ

**ភ្នំពេញ ថ្ងៃទី 12 ខែវិច្ឆិកា ឆ្នាំ 2021** – ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក (“អេ អាយ អេ ខេមបូឌា”)និង ធនាគារកម្ពុជាសាធារណៈ បន្តភាពជាដៃគូអាជីវកម្មប៉េងកាសួរេន ដើម្បីជួយ ឲ្យមានកំណើនការប្រើប្រាស់សេវាធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការផ្តល់ដំណោះស្រាយហិរញ្ញវត្ថុរយៈពេលវែង និងកាន់តែទូលំទូលាយជូនអតិថិជន។

អេ អាយ អេ ខេមបូឌា គឺជាដៃគូអាជីវកម្មប៉េងកាសួរេនផ្តាច់មុខរបស់ធនាគារកម្ពុជាសាធារណៈ តាំងពីឆ្នាំ ២០១៧ ហើយឥឡូវនេះត្រូវបន្តរយៈពេល ១៥ ឆ្នាំទៀត ដើម្បីពង្រឹងភាពជោគជ័យនៃកិច្ចសហការនេះ។ ក្រុមហ៊ុនទាំងពីរនឹងផ្តល់គុណតម្លៃបន្ថែមជូនអតិថិជនតាមរយៈ ការបន្តបង្កើនការយល់ដឹងអំពីសេវាធានារ៉ាប់រង និងការពង្រឹងសេវាកម្មរបស់ខ្លួនក្នុងនាមជាដៃគូអាជីវកម្មប៉េងកាសួរេន ឈានមុខគេក្នុងប្រទេសកម្ពុជា។

ជាមួយនឹងការបន្តភាពជាដៃគូនេះ អតិថិជនរបស់ធនាគារកម្ពុជាសាធារណៈ អាចបន្តទទួលបានផលិតផលធានារ៉ាប់រង និងការប្រឹក្សារបស់ អេ អាយ អេ ខេមបូឌា កាន់តែងាយស្រួល រួមជាមួយការផ្តល់ជូនពិសេសនានា និងសេវាកម្មល្អៗជាច្រើន ពីក្រុមហ៊ុនទាំងពីរនេះ។ ភាពជាដៃគូនេះដើរតួនាទីជាកន្លែងផ្តល់សេវាកម្មសម្រាប់បុគ្គល និងក្រុមហ៊ុននានាក្នុងការទទួលបានទាំងសេវាកម្មធនាគារដែលមានគុណភាពខ្ពស់ និងដំណោះស្រាយធានារ៉ាប់រងអាយុជីវិតដែលស្របតម្រូវការហិរញ្ញវត្ថុរបស់ពួកគេនៅកន្លែងតែមួយ។

ពិធីចុះហត្ថលេខានេះ មានការចូលរួមពីថ្នាក់ដឹកនាំនៃក្រុមហ៊ុនទាំងសងខាង រួមនិងអតិថិជនបួននាក់ដំបូងផងដែរ។ អតិថិជនទាំងបួននាក់បានសម្តែងនូវភាពសប្បាយរីករាយ និងការពេញចិត្តជាខ្លាំងក្នុងការទទួលបានការការពារផ្នែកហិរញ្ញវត្ថុ ហើយបន្តការប្រើប្រាស់រហូតដល់សព្វថ្ងៃនេះ។

ក្នុងពិធីចុះហត្ថលេខានេះ លោក Andrew Loh អគ្គនាយកប្រតិបត្តិនៃក្រុមហ៊ុន អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា “ភាពជាដៃគូរបស់យើងមិនត្រឹមតែពង្រឹងការប្តេជ្ញាចិត្តចំពោះអតិថិជនរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយឱ្យយើងពង្រឹងការខិតខំប្រឹងប្រែងរបស់យើងដើម្បីជួយប្រជាជនកម្ពុជាឱ្យមានសុខភាព និងជីវិតកាន់តែប្រសើរឡើង។ សូមអរគុណដល់ធនាគារកម្ពុជាសាធារណៈ ហើយឥឡូវនេះយើងមានជំហរកាន់តែរឹងមាំក្នុងការផ្សព្វផ្សាយអំពីសារៈសំខាន់នៃសេវាធានារ៉ាប់រងអាយុជីវិត និងផ្តល់ជូនវេទិកាហិរញ្ញវត្ថុដ៏មានអត្ថប្រយោជន៍ ដើម្បីការពារសុខុមាលភាពនាពេលអនាគតរបស់ប្រជាជនកម្ពុជាឲ្យបានកាន់តែច្រើន។”

លោក Ong Ming Teck អគ្គនាយកប្រតិបត្តិនៃធនាគារកម្ពុជាសាធារណៈ មានប្រសាសន៍ថា “កិច្ចសហការរបស់យើងជាមួយ អេ អាយ អេ ខេមបូឌា នឹងបំពេញបន្ថែមនូវបទពិសោធន៍សេវាកម្មហិរញ្ញវត្ថុដ៏ងាយស្រួល និងទូលំទូលាយ។

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

ធនាគារកម្ពុជាសាធារណៈ ផ្ដោតការយកចិត្តទុកដាក់ជាខ្លាំងទៅលើសេវាកម្មជូនអតិថិជន ហើយយើងនឹងបន្តផ្តល់សេវាកម្ម ក៏ដូចជាផលិតផលប្រកបដោយភាពច្នៃប្រឌិត ដែលស្របតាមតម្រូវការអតិថិជនរបស់យើង។ ការបន្តភាពជាដៃគូនេះ នឹងជួយអតិថិជនបំពេញតម្រូវការសន្សំ និងការការពារបន្ថែមទៀត។"

ដើម្បីធ្វើឲ្យភាពជាដៃគូនេះកាន់តែមានអត្ថន័យ អេ អាយ អេ ខេមបូឌា និងធនាគារកម្ពុជាសាធារណៈ នឹងចូលរួមថវិកាសរុប $10,000 ដល់យុទ្ធនាការ Fit for Hope របស់ក្រុមហ៊ុន អេ អាយ អេ ខេមបូឌា ដែលជាយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ទូទាំងប្រទេស និងជារៀងរាល់ខែតុលា។

សម្រាប់ព័ត៌មានបន្ថែមអំពីការផ្តល់ជូនរបស់ អេ អាយ អេ ខេមបូឌា តាមរយៈធនាគារកម្ពុជាសាធារណៈ និងរបៀបដែលពួកគេអាចធ្វើការដើម្បីផលប្រយោជន៍ហិរញ្ញវត្ថុរបស់អ្នក សូមទាក់ទងសេវាកម្មអតិថិជនរបស់ អេ អាយ អេ តាមរយៈលេខ 086 999 242 ឬចូលទៅកាន់គេហទំព័រ aia.com.kh ។

***អំពី អេ អាយ អេ***

*អេ អាយ អេ គ្រុប លីមីតធីត និង សាខា (តទៅហៅថា អេ អាយ អេ "AIA" ឬ គ្រុប "Group") មានក្រុមហ៊ុនធានារ៉ាប់រងជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន ១៨ ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង និង ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅទីក្រុងហុងកុង SAR ប្រទេសថៃ សឹង្ហបូរី ម៉ាឡេស៊ី ចិនដីគោក កូរ៉េខាងត្បូង ហ្វីលីពីន អូស្ត្រាលី ឥណ្ឌូនេស៊ី (ចិន) តៃវ៉ាន់ វៀតណាម ញ៉ូហ្ស៊ីលែន ម៉ាកាវ SAR ប្រ៊ុយណេ កម្ពុជា មីយ៉ាន់ម៉ា ក្រុមហ៊ុនបុត្រសម្ព័ន្ធដែល ៩៩ ភាគរយនៅប្រទេសស្រីលង្កា និង ក្រុមហ៊ុនបណ្ដាក់ទុនរួម ៤៩ ភាគរយនៅប្រទេសឥណ្ឌា។*

*ក្នុងពេលបច្ចុប្បន្ន អាជីវកម្មរបស់ក្រុមហ៊ុន គឺដូចគ្នានិង អេអាយអេ ដែលត្រូវបានបង្កើតឡើងលើកដំបូងនៅទីក្រុងសៀងហៃកាលពីមួយសតវត្សកន្លងទៅក្នុងឆ្នាំ ១៩១៩ ។ ជាក្រុមហ៊ុនឈានមុខគេមួយនៅលើទីផ្សារ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (អតីត-ជប៉ុន) ដោយផ្ដោតទៅលើបុព្វលាភធានារ៉ាប់រងជីវិត និង មានតួនាទីនាំមុខគេនៅគ្រប់ទីផ្សារភាគច្រើនរបស់ខ្លួន ។ ក្រុមហ៊ុនមានទ្រព្យសម្បត្តិសរុបចំនួន ៣២៦ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។*

*អេ អាយ អេ ឆ្លើយតបតាមតម្រូវការនៃប្រាក់សន្សំ និង ការការពាររយៈពេលវែងរបស់ ពលរដ្ឋទូទៅតាមរយៈការផ្ដល់នូវផលិតផលដ៏សម្បូរបែប និង សេវាកម្មជាច្រើនរួមមាន ការធានារ៉ាប់រងជីវិត គ្រោះថ្នាក់ ការធានារ៉ាប់រងសុខភាព និង ផែនការសន្សំប្រាក់ ។ ក្រុមហ៊ុនគ្រុប ក៏ផ្ដល់ផងដែរនូវប្រាក់អត្ថប្រយោជន៍សម្រាប់បុគ្គលិក ផ្ដល់ឥណទានអាយុជីវិត និង សេវាកម្មប្រាក់សោធនិវត្តន៍ ។ តាមរយៈបណ្ដាញភ្នាក់ងារ ដៃគូ និង បុគ្គលិកដ៏ទូលំទូលាយនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក អេអាយអេ បានផ្ដល់ដល់ម្ចាស់ប័ណ្ណធានានូវ ប័ណ្ណធានារ៉ាប់រងរូបវន្តបុគ្គលច្រើនជាង ៣៨ លាននាក់ និង សមាជិកដែលបានចូលរួម ផែនការធានារ៉ាប់រងជាក្រុមជាង ១៦ លាននាក់។*

*អេ អាយ អេ គ្រុបលីមីតធិត (AIA Group Limited) ត្រូវបានដាក់បញ្ចូលក្នុង តារាងនៃក្រុមប្រឹក្សាភិបាលចម្បងនៃ គណកម្មាធិការផ្សារមូលបត្រទីក្រុងហុងកុង (Main Board of The Stock Exchange of Hong Kong Limited) ដែលស្ថិតក្រោមច្បាប់ផ្សារមូលបត្រ "១២៩៩" ស្របតាមច្បាប់ស្ដីពី ការទទួលប្រាក់តម្កល់នៃសហរដ្ឋអាមេរិក (កម្រិត ១) A (American Depositary Receipts (Level 1) ដែលធ្វើពាណិជ្ជកម្មលើទីផ្សារស្របច្បាប់ (រូបសញ្ញា: "AAGIY")។*

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

**ទំនាក់ទំនងសារព័ត៌មាន**
**ម៉េង ដាណែត**
ប្រធានផ្នែកទីផ្សារជាន់ខ្ពស់
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
Daneth-d.Meng@aia.com